ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកា

# តាមនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ២១៧

ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០

សាលដីកា

លេខ ៨៩ VIII

ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.លោកជំទាវ [redacted] ជាប្រធាន

២.ឯកឧត្តម [redacted] ជាចៅក្រម

៣.ឯកឧត្តម [redacted] ជាចៅក្រម

៤.ឯកឧត្តម [redacted] ជាចៅក្រមរបាយការណ៍

៥.លោកជំទាវ [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៤១១ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] NASWALL ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៥៦ "ក្រV ទល" ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន ៖

**ជនជាប់ចោទ** ៖ ឈ្មោះ [redacted] NASWALL (ប្រាយអិន ដារីវ ណាស្វែល) ភេទប្រុស អាយុ ៥៣ឆ្នាំ ជនជាតិអាមេរិក មុខរបរភាគហ៊ុនអាកាសចរ AERO CAMBODIA AIRLING មានទីកន្លែងកំណើតនៅទីក្រុង Winnipig ខេត្តManatoba ប្រទេសកាណាដា មានទីលំនៅបច្ចុប្បន្ន [redacted] ជាន់ទី០៦ អគារ៥ ផ្លូវលេខ១១ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] "លែងលះ" មានកូន ០១នាក់ ទោសពីមុនគ្មាន ។ (អ្នកប្តឹងសាទុក្ខ)



Scanned with CamScanner

.ឃុំខ្លួននៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ នៅពន្ធនាគារព្រៃស ម១ ។

**ដាច់ចោទពីបទ៖** ទិញពេស្យាចារកុមារ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១១ ឆ្នាំ២០១៣ ឆ្នាំ២០១៥ និងជាក់ស្តែងនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

-មានលោកមេធាវី [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-មានអ្នកបកប្រែភាសាខ្មែរ-អង់គ្លេសលោកស្រី[redacted]ឫទ្ធារស្មី ។

**ដើមបណ្តឹងរដ្ឋប្បវេណី ៖**

១.ឈ្មោ[redacted] វឿន ភេទស្រី អាយុ៣៧ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅភូមិសំរោង ឃុំខ្សឹម ស្រុកស្នួល ខេត្តក្រចេះ ។

២.ឈ្មោះ [redacted]ហាន់នី ភេទស្រី អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅផ្ទះលេខ០១ ផ្លូវលេខ២១១ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

៣.ឈ្មោ[redacted] រំដួល ភេទស្រី អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅស្នាក់នៅផ្ទះជួល ភូមិ១ សង្កាត់ជ្រោយចង្វារ រាជធានីភ្នំពេញ។

៤.ឈ្មោ[redacted]សុខុន ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅស្នាក់នៅផ្ទះជួល ភូមិ១ សង្កាត់ជ្រោយចង្វារ រាជធានីភ្នំពេញ។

៥.ឈ្មោ[redacted]សុខា ភេទស្រី អាយុ២៥ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅស្នាក់នៅ ភូមិ១២ (បុរីកីឡា) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

៦.ឈ្មោ[redacted]ស្រី ភេទស្រី អាយុ៤៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅស្នាក់នៅផ្ទះជួល ភូមិ២ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

៧.ឈ្មោះ [redacted] ឃាន ភេទស្រី អាយុ៤៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅភូមិសារាយ ឃុំបុស្សខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម។

**ជនរងគ្រោះ ៖**

១.ឈ្មោះ [redacted]ស្រីម៉ៅ ភេទស្រី អាយុ៥១ឆ្នាំ កើតថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០០ សញ្ជាតិខ្មែរ មានទីលំនៅស្នាក់ [redacted] ផ្លូវលេខ៥៧២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

២.ឈ្មោះ [redacted] មុនីរ័ត្ន ភេទស្រី អាយុ៥ឆ្នាំ កើតថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ សញ្ជាតិខ្មែរ មានទីលំនៅភូមិ [redacted]។

៣.ឈ្មោះ [redacted]ស្រីឃីម ភេទស្រី អាយុ៧ឆ្នាំ កើតថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ សញ្ជាតិខ្មែរ មានទីលំនៅ [redacted]



Scanned with CamScanner

៤.ឈ្មោះ[redacted]សុភីមីជុតិមុន្នី ភេទស្រី អាយុ៦ឆ្នាំ កើតថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ សញ្ជាតិខ្មែរ មានទី[redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ។

៥.ឈ្មោះ[redacted]ស្រីណែត ភេទស្រី អាយុ១៣ឆ្នាំ កើតឆ្នាំ២០០២ សញ្ជាតិខ្មែរ [redacted] សង្កាត់ជ្រោយចង្វារ រាជធានីភ្នំពេញ។

៦.ឈ្មោះ [redacted] សុភ័ក្ត្រ ភេទស្រី អាយុ១៦ឆ្នាំ សញ្ជាតិខ្មែរ (ស្នាក់នៅសហគមន៍ទឹកដីសន្យា) ផ្ទះលេខ [redacted] សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

៧.ឈ្មោះ[redacted]ស្រីស្រស់ ភេទស្រី អាយុ១៥ឆ្នាំ សញ្ជាតិខ្មែរ (ស្នាក់នៅសហគមន៍ទឹកដីសន្យា) ផ្ទះលេខ [redacted] សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

៨.ឈ្មោះ[redacted]ស្រីល័ក្ខ ភេទស្រី អាយុ១៣ឆ្នាំ សញ្ជាតិខ្មែរ (ស្នាក់នៅសហគមន៍ទឹកដីសន្យា) ផ្ទះលេខ [redacted]សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

៩.ឈ្មោះ[redacted]ស្រីពៅ ភេទស្រី អាយុ១៣ឆ្នាំ កើតថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០២ សញ្ជាតិខ្មែរ (ស្នាក់នៅ[redacted]ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

**អំពីអង្គហេតុ**

កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ វេលាប្រហែល ១៩និង ០០នាទី នៅចំណុចកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ[redacted] NASWALL ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិអាមេរិក បានជិះម៉ូតូធំឌុបកុមាររងគ្រោះចំនួន បីនាក់ មានឈ្មោះ[redacted] ស្រីល័ក្ខ ភេទស្រី អាយុ១៣ឆ្នាំ, ឈ្មោះ[redacted]សុភ័ក្ត្រ ភេទស្រី អាយុ១៦ឆ្នាំ និងឈ្មោះ[redacted]ស្រីរ័ត្ន ភេទស្រី អាយុ១៥ឆ្នាំ ដើរលេង ហូបចំណី និងទិញសំភារៈផ្សេងៗឱ្យទៅជនរងគ្រោះ។ ពេលមកដល់កោះពេជ្រកន្លែងស្ងាត់ ខាងក្រោយឃ្លាំងដាក់ឥវ៉ាន់ ជនសង្ស័យឈ្មោះ[redacted] Naswall ក៏បានឈប់ម៉ូតូរួចក៏[redacted]មាររងគ្រោះវិញ ដោយកុមាររងគ្រោះឈ្មោះ[redacted] ស្រីល័ក្ខ ដាក់អង្គុយលើម៉ូតូ រួចជនជាប់ចោទបាន[redacted]វិញ។ ជនជាប់ចោទបានសន្យាឱ្យប្រាក់ទៅកុមាររងគ្រោះទាំងអស់នោះក្នុងម្នាក់ៗចំនួន ១៥ ដុល្លាអាមេរិក ទៅ ២០ ដុល្លាអាមេរិក ក្រោយពីជនសង្ស័យឈ្មោះ[redacted] Naswall បានធ្វើសកម្មភាពបានប្រហែល ០៧នាទី ក៏ត្រូវសមត្ថកិច្ចចូលទៅធ្វើការឃាត់ខ្លួនតែម្តង។ កន្លងមកនៅក្នុងឆ្នាំ២០១១, ឆ្នាំ២០១៣, ឆ្នាំ២០១៥ ជនជាប់ចោទឈ្មោះ[redacted] Naswall ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិអាមេរិក ក៏បានធ្វើសកម្មភាពដូចនេះទៅលើកុមាររងគ្រោះជាច្រើននាក់ផ្សេងទៀតមកហើយ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ២១៣ "ច" ក្រ.ក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

Scanned with CamScanner

១-ផ្តន្ទាទោសឈ្មោះ[redacted] Naswall ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិអាមេរិក ដាក់ពន្ធនាគារ កំណត់រយៈពេល ១០ (ដប់) ឆ្នាំ ពីបទ ការទិញពេស្យាចារកុមារ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១១ ឆ្នាំ២០១៣ ឆ្នាំ២០១៥ និងជាក់ស្តែងនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២.បង្គាប់ឱ្យឈ្មោ[redacted] Naswall សងការខូចខាត និងជម្ងឺចិត្តទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោម៖

ក.ឈ្មោះ[redacted] សុខន ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល

ខ.ឈ្មោះ[redacted] ស្រី ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល

គ.ឈ្មោះ[redacted]សុខា ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល

ឃ.ឈ្មោះ[redacted] ឃាន ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល

ង.ឈ្មោះ[redacted]វៀន ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល

ច.ឈ្មោះ[redacted]វ៉ូហាន់នី ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល

ច្រានចោលការទាមទារលើសពីនេះ។

៣.វត្ថុតាងរួមមាន៖

ក.វត្ថុតាងសម្រេចរឹបអូសមាន៖

-Speaker (ប្រដាប់បំពងសម្លេងចំនួន០២)

-មេម៉ូរីចំនួន 0៤ (ម៉ាក Panasinic 1GB . Wintec 4GB . Scandisk 4GB . ០១គ្រឿងទៀតមិនស្គាល់ម៉ាក)។

-CardReader ចំនួន 0២ (ម៉ាក Targus និងម៉ាកSiyoteam), ផ្លាសពណ៌ខ្មៅចំនួន ០១ ជើង Memory ចំនួន០១ និងស៊ីមកាតចំនួន០៣។

-លឹង្គសិប្បនិម្មិត ចំនួន 0២ និងថ្នាំម៉ាក KY ០១ ប្រអប់, ស្រោមអនាម័យចំនួន 0៥។

-ដំបងដែកចំនួន០១, កាំបិតបត់ចំនួន០៣, កាំភ្លើងជ័រចំនួន០១ និងពិលចំនួន០១។

-សៀវភៅកំណត់ហេតុចំនួន០៥ក្បាល និងត្រាចំនួន០១។

-ឯកសារផ្សេងៗមួយចំនួន, ឌីសមួយចំនួន, នាមប័ណ្ណមួយចំនួនធំ និងឯកសណ្ឋានអាវប្រយុទ្ធ ០១ អាវ ប៉ារ៉ា 0២។

ខ.វត្ថុតាងដែលត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ មាន៖

-ប៉ាស្ព័រមួយក្បាលលេខ ៤៥៣៦៥១៥៩១ របស់ឈ្មោះ NASWALL [redacted] ប័ណ្ណបើកបរ របស់ឈ្មោះ NASWALL [redacted] ចំនួន០១, កាតអេធីអឹមធនាគារវឌ្ឍនៈរបស់ឈ្មោះ NASWALL [redacted] ចំនួន០១, Passsport Card របស់ឈ្មោះ NASWALL [redacted] ចំនួន០១។



Scanned with CamScanner

-ម៉ូតូមួយគ្រឿងម៉ាក Honda XL 125 ពណ៌ស្ពាន់ទុំ ពាក់ស្លាកលេខ ភព១ ទ៦១២៧។

-លុយចំនួន ០៣ ដុល្លារអាមេរិក និងលុយខ្មែរចំនួន ១៨.៥០០ រៀល។

៤-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ ជនរងគ្រោះ មេធាវីការពារជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦។

បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៤៤១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] NASWALL ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២១៣ "ច"ក្រ៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៥៦ "ក្រ V ១ល" ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៤១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ របស់ឈ្មោះ[redacted] Naswall ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២១៣ "ច"ក្រ៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

៣-បន្តឃុំខ្លួនឈ្មោះ [redacted] Naswall ដែលមានសាវតាជាតិដូចខាងលើតាមនីតិវិធី។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ចំពោះមុខឈ្មោះ[redacted] Naswall និងចាត់ទុកជាចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]សុខន,[redacted]ស្រី,[redacted]សុខា,[redacted]ឃាន,[redacted]វឿន, [redacted]វ៉ូហាន់ធី។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៤១១ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted]ASWALL ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៥៦ "ក្រV ១ល" ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើសេចក្តីសន្និដ្ឋានថា៖ ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ ដែលបានតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការនេះ គឺមានសំអាងហេតុ និងភស្តុតាងត្រឹមត្រូវតាមច្បាប់ ។ តាមចម្លើយរបស់កុមារីរងគ្រោះទាំងអស់បង្ហាញឱ្យឃើញថា ជនជាប់ចោទពិត

ក្រមប្រឹក្សា
តុលាការកំពូល

Scanned with CamScanner

ជាបានប្រព្រឹត្តអំពើទិញពេស្យាចារកុមារដូចបទចោទពិតមែន ដូចមានក្នុងសំអាងហេតុចំណុចទី២ និងទី៣ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់ ។ ចម្លើយបដិសេធរបស់ជនជាប់ចោទ គ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ។

ហេតុដូច្នេះ តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៥៦ "ក្រV១ល" ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ ទុកជាបានការដែល ។

+ជនជាប់ចោទឈ្មោះ [redacted] NASWALL បានឆ្លើយថា៖ ខ្លួនមិនសុខចិត្តនឹងការដែលប្តឹងចោទប្រកាន់ខ្លួនដោយពុំមានភស្តុតាងចោទប្រកាន់ឡើយ ខ្លួនស្គាល់តែក្មេងស្រី៣នាក់ទេ ចំពោះក្មេងស្រីដទៃទៀតខ្លួនមិនបានដឹងថាពួកគេមកពីណាទេ ខ្លួនធ្លាប់បានសួរនាំ និងបានប្រគល់ប្រាក់ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីដែរ ។ ខ្លួនបានទៅដល់អង្គការមួយហើយបានកូពីក្រដាស និងមានទំនាក់ទំនងជាមួយក្មេងស្រីទាំងនោះ ស្រាប់តែមានប៉ូលីសមកហ៊ុំព័ទ្ធរួចមកសួរថា តើខ្លួនមានទំនាក់ទំនងអ្វីជាមួយក្មេងស្រីទាំងអស់នោះ? គេបានឧបត្ថម្ភប្រាក់ឱ្យខ្លួនយកទៅជួយអង្គការនោះ ។ កាលពីល្ងាចម៉ោង ៧ ខ្លួនបានដឹកកុមារទៅដើរលេង និងបាននាំទៅញ៉ាំអាហារបន្ទាប់មកក៏មានNGOមកឃាត់ និងសួរនាំខ្លួន កាលនៅកោះពេជ្រនោះមិនស្គាល់ទេ មានមនុស្សម្នារទៅមក ពេលនោះប៉ូលីសបានជូនក្មេងស្រីទៅអង្គការវិញ ហើយក៏បាននាំខ្លួនទៅឆ្លើយសារភាពនៅតុលាការ ខ្លួនមិនមែនមកកាន់ប្រទេសកម្ពុជាក្នុងគោលបំណងអាក្រក់ទេ គឺខ្លួនមកដើម្បីធ្វើជំនួញ ។

សំណូមពរ សូមតុលាការជួយរកយុត្តិធម៌ដល់ខ្លួនផង ។

+លោក [redacted] ម៉ូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ បទចោទពាក់ព័ន្ធនឹងអង្គហេតុក្នុងឆ្នាំ២០១១, ឆ្នាំ២០១៣ និងឆ្នាំ២០១៥ មានជនរងគ្រោះអាយុចាប់ពី ៥ឆ្នាំ ដល់ ១៦ឆ្នាំ អង្គហេតុឆ្នាំ២០១៥ មានជនរងគ្រោះតែ៣នាក់ទេ ហើយសាលាឧទ្ធរណ៍ក៏បានផ្តោតជាសំខាន់លើអង្គហេតុឆ្នាំ២០១៥ ដោយយកសក្ខីកម្មជនរងគ្រោះនៃអំពើឆ្នាំ២០១១ និង២០១៣ មកគាំទ្រ ។ យុត្តិសាស្ត្ររបស់តុលាការកំពូលសក្ខីកម្មរបស់ជនរងគ្រោះតែមួយមុខសម្រាប់សម្រេចទោសលើជនជាប់ចោទ មិនត្រឹមត្រូវទេ ទាមទារឱ្យមានភស្តុតាងបន្ថែមទៀតគាំទ្រ ក្នុងរឿងនេះកើតមានតាំងពីឆ្នាំ២០១១ ដែលជនរងគ្រោះខ្លះមកដល់ថ្ងៃសវនាការរយៈពេលជាង ១០ឆ្នាំ ។ កូនក្តីខ្លួនបានឆ្លើយបដិសេធគ្រប់ដំណាក់កាលថា គាត់មិនបានប្រព្រឹត្ត នេះបង្ហាញពីភាពផ្ទុយគ្នាខ្លាំងរវាងជនរងគ្រោះ និងជនល្មើស ឃើញថាមានការភ័ន្តច្រឡំលើបន្ទុកភស្តុតាង ការទាមទារឱ្យជនជាប់ចោទដាក់ភស្តុតាងដោះបន្ទុកនេះ នាំឱ្យមានសេចក្តីសន្និដ្ឋានអវិជ្ជមាន និងប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ។ តុលាការកំពូល ពិនិត្យមើលលើអង្គច្បាប់ និងផ្អែកជាសំខាន់លើឯកសារភស្តុតាង ក្នុងសំណុំរឿងដែលមានភស្តុតាងដាក់បន្ទុកក្នុងសំណុំរឿងនេះ មានចំនួនច្រើន ក៏ប៉ុន្តែខ្វះនូវភាពជឿជាក់បាន មិនគាំទ្រគ្នារឹងមាំដែលអាចនាំឱ្យចៅក្រម មានហេតុផលអាចជឿបានថា បទល្មើសត្រូវបានប្រព្រឹត្តក្នុងកម្រិតមួយខ្ពស់ និងប្រព្រឹត្តដោយ Naswall តាមខ្លឹមសារនៃមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សំណូមពរ សូមតុលាការកំពូលសម្រេចបញ្ជូនសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះឡើងវិញ ។



Scanned with CamScanner

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.យល់ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] NASWALL ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.យល់ឃើញថា តំណាងមហាអយ្យការអមតុលាការកំពូលបានសន្និដ្ឋាននាពេលសវនាការថា ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ដែលបានតម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការដែល គឺមានសំអាងហេតុ និងភស្តុតាងត្រឹមត្រូវតាមច្បាប់ ហើយតាមចម្លើយរបស់កុមារីរងគ្រោះទាំងអស់បង្ហាញឱ្យឃើញថា ជនជាប់ចោទពិតជាបានការប្រព្រឹត្តអំពើទិញពេស្យាចារកុមារដូចបទចោទពិតមែន ដូចមានក្នុងកំណត់ហេតុចំណុចទី២ និងទី៣ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់ ។ ចំពោះចម្លើយបដិសេធរបស់ជនជាប់ចោទ គ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ ។

៣.យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ភ្នំពេញសម្រេច *"តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២១៣ "ច" ក្រ៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ដោយសំអាងថា ចម្លើយរបស់ជនរងគ្រោះ [redacted] ស្រីលក្ខណ៍ និង [redacted] សុភ័ក្រ បានឆ្លើយប្រហាក់ប្រហែលគ្នាថា ជនជាប់ចោទនាំខ្លួនដើរលេង គ្រប់ម៉ោង ជនជាប់ចោទនាំខ្លួនទៅជិះម៉ូតូជាមួយ នាំខ្លួនទៅលេងកោះពេ [redacted] ចគាត់ឱ្យលុយ ៥ដុល្លារ នៅកន្លែងស្ងាត់ៗ ៤ ទៅ ៥ដង តែជនជាប់ចោទមិនដែលរួមភេទជាមួយខ្លួនទេ ដែលស៊ីសង្វាក់នឹងចម្លើយសាក្សីផ្សេងៗទៀត"* នោះ គឺជាការមិនត្រឹមត្រូវទេ ពីព្រោះថា សាលាឧទ្ធរណ៍ភ្នំពេញ ពុំបានពិចារណាអំពី៖

ក.បទចោទប្រកាន់លើជនជាប់ចោទអំពីអង្គហេតុដែលប្រព្រឹត្តនៅអំឡុងឆ្នាំ២០១១ ឆ្នាំ២០១៣ ឆ្នាំ២០១៥ និងជាក់ស្តែង នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ ប៉ុន្តែអង្គហេតុដែលបញ្ជូនមកជំនុំជម្រះ គឺលើកតែអង្គហេតុដែលកើតនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ ប៉ុណ្ណោះ ។

ខ.ភស្តុតាងសម្រាប់បទល្មើសដែលកើត នៅឆ្នាំ២០១១ និងឆ្នាំ២០១៣ មិនត្រូវប្រើប្រាស់ជាភស្តុតាងសម្រាប់បទល្មើសដែលកើតនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ ឡើយ ។

គ.ជនរងគ្រោះ នៃថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ ឃើញមានតែចំនួន ៣នាក់ ប៉ុណ្ណោះ ។

៤.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៥៦ "ក្រV ទល" ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលសម្រេចសេចក្តីមកនេះមិនត្រឹមត្រូវតាមច្បាប់ឡើយ ។



Scanned with CamScanner

## ហេតុដូច្នេះ

## សម្រេច

១.ទទួលបណ្តឹងសាទុក្ខលេខ ៤១១ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោ[redacted]NASWALL ។

២.បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៥៦ “ក្រV ទល” ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ។

៣.បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ២១៧ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ ។

សាលដីកានេះបានជំនុំជម្រះ នៅថ្ងៃទី១៧ ខែកុម្ភៈ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ។

| | | |
|---|---|---|
| -លោកជំទាវ | [redacted] | ជាប្រធាន |
| -ឯកឧត្តម | [redacted] | ជាចៅក្រម |
| -ឯកឧត្តម | [redacted] | ជាចៅក្រម |
| -ឯកឧត្តម | [redacted] | ជាចៅក្រម |
| -លោកជំទាវ | [redacted] | ជាចៅក្រម |
| -លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ថ្ងៃពុធ ១២កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ថ្ងៃពុធ ១២កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner